**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

លេខ ០៥០ សណស.អគថ

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ២០០៣

# ប្រកាស
## ស្តីពី
## ការដាក់អោយអនុវត្តនូវកម្មវិធីសិក្សាគិលានុបដ្ឋាក-ឆ្មប បឋម
***
## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០-១១-៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស / រកម ០១៩៦ / ០៦ ចុះថ្ងៃទី ២៤-០១-៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ. បក ចុះថ្ងៃទី ២២-១០-៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញលិខិតលេខ ១១៧ ស.ស.រ ចុះថ្ងៃទី ២៥-០៧-៨៨ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការយល់ព្រមអោយបង្កើតសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគឥសាន្តខេត្តស្ទឹងត្រែង
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ. បក ចុះថ្ងៃទី ៣០- ១២- ២០០២ ស្តីពីការគ្រប់គ្រងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ
- បានឃើញប្រកាសលេខ ៣១១សនប ចុះថ្ងៃទី២៨-០៥-២០០៣ ស្តីពីការរៀបចំនិងការប្រព្រឹត្ត ទៅរបស់សាលាមធ្យមសិក្សាសុខាភិបាល ភូមិភាគ
- យោងតាមការចាំបាច់របស់ក្រសួង

## <u>សំរេច</u>

ប្រការ ១.- ដាក់អោយអនុវត្តនូវកម្មវិធីសិក្សា គិលានុបដ្ឋាក-ឆ្មប បឋម ដែលមានរយៈពេលមួយឆ្នាំ សំរាប់ភូមិភាគឥសាន្ត ដែលស្ថិតនៅក្នុងតំបន់គ្របដណ្តប់ ដោយសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ ស្ទឹងត្រែង ចាប់ពី ឆ្នាំសិក្សា ២០០៣-២០០៤ នេះតទៅ ។

ប្រការ ២.- វគ្គបណ្តុះបណ្តាលគិលានុបដ្ឋាក-ឆ្មប បឋម ត្រូវធ្វើនៅតាមមន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង រតនៈគីរី មណ្ឌលគីរី និងព្រះវិហារ ដោយមានការអភិបាលបច្ចេកទេសពី សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគស្ទឹងត្រែង ។

ប្រការ៣.- សិស្សដែលបានប្រឡងបញ្ចប់ការសិក្សា វគ្គគិលានុបដ្ឋាក-ឆ្មប បឋម ដោយជោគជ័យ ត្រូវបានទទួលសញ្ញាប័ត្រ ជាគិលានុបដ្ឋាកបឋម ឬ ឆ្មបបឋម ដែលចេញដោយក្រសួងសុខាភិបាល ។

ប្រការ ៤.- នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស មានភារៈកិច្ច អភិវឌ្ឍន៍ និង គ្រប់គ្រង កម្មវិធីបណ្តុះបណ្តាលគិលានុបដ្ឋាក-ឆ្មប បឋម អោយមានដំណើរការល្អ ដោយមានការសហការណ៍ពីសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ ស្ទឹងត្រែង មន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង រតនៈគីរី មណ្ឌលគីរី និង ព្រះវិហារ ។

ប្រការ ៥.-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ សាលាមធ្យមសិក្សាសុខាភិបាល ភូមិភាគស្ទឹងត្រែង មន្ទីរសុខាភិបាលខេត្ត ស្ទឹងត្រែង រតនៈគីរី មណ្ឌលគីរី និង ព្រះវិហារ មានភារៈកិច្ច អនុវត្ត តាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។៤.៤

ជ. រដ្ឋមន្ត្រីក្រសួងសុខាភិបាល

រដ្ឋលេខាធិការ

វេជ្ជ.ម៉ម ប៊ុនហេង

ចំលងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- គ្រប់សាលាខេត្ត ពាក់ពន្ធ័
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- ដូចប្រការ ៥
- ឯកសារ
- កាលប្បវត្តិ